# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦
## ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ២៥៧០
## ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ នៅវិមានមិត្តភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងកិច្ចប្រជុំនាពេលនេះ!

ឆ្លងកាត់ការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹកនេះ កិច្ចប្រជុំពេញអង្គរបស់យើងបានស្តាប់នូវបទបង្ហាញ ព្រមទាំងបានពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ សមស្របទៅនឹងកម្មវត្ថុដែលបានគ្រោងទុក។ ក្នុងនាមអង្គពិធី ខ្ញុំសូមសង្ខេបជូននូវលទ្ធផលគន្លឹះជាយុទ្ធសាស្ត្រចំនួន ២ ដូចតទៅ៖

- ទី១.ការអនុម័តលើរបាយការណ៍វឌ្ឍនភាព៖ អង្គប្រជុំបានឯកភាពអនុម័តជាគោលការណ៍ លើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២៥ កន្លងទៅ។
- ទី២.ការដាក់ចេញទិសដៅថ្មី៖ អង្គប្រជុំបានឯកភាពដាក់ចេញនូវសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦ នេះ ដើម្បីជាត្រីវិស័យសម្រាប់ការងារបន្ត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា អង្គពិធីទាំងមូលជាទីគោរព និងជាទីមេត្រី**!

ទោះបីជាយើងមានពេលវេលាសម្រាប់ពិភាក្សាគ្នាតែមួយព្រឹកក៏ពិតមែន ប៉ុន្តែការចូលរួមយ៉ាងសកម្ម និងការផ្តល់មតិយោបល់ប្រកបដោយខ្លឹមសារពីសំណាក់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** បានធ្វើឱ្យកិច្ចប្រជុំដ៏មានតម្លៃរបស់យើងនាថ្ងៃនេះ ទទួលបានលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ។

ខ្ញុំសូមឆ្លៀតយកឱកាសដ៏វិសេសវិសាលនេះ សម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុត និងវាយតម្លៃខ្ពស់ចំពោះស្មារតីទទួលខុសត្រូវរបស់សមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ដើម្បីឈានទៅសម្រេចបាននូវគោលដៅលុបបំបាត់ជំងឺអេដស៍ កម្ពុជាចាំបាច់ត្រូវមានកម្មវិធី និងគោលនយោបាយជាតិនានា ដែលបង្កើតបានជាបរិយាកាសអំណោយផលជាវិជ្ជមាន សំដៅជួយសម្រួលដល់ការឆ្លើយតបឱ្យប្រព្រឹត្តទៅដោយរលូន តាមរយៈ៖

- **ការលុបបំបាត់របាំងវិសមភាពសង្គម** និងការរើសអើងក្នុងការទទួលសេវាថែទាំ និងព្យាបាល។
- **ការចូលរួមចំណែកពង្រឹងការឆ្លើយតបឱ្យបានទ្វេដង** ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ក្នុងន័យនេះ ខ្ញុំសូមបន្តអំពាវនាវយ៉ាងទទូចដល់ថ្នាក់ដឹកនាំគ្រប់ស្ថាប័នជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ត្រូវចូលរួមយ៉ាងសកម្មក្នុង **«ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»** ដើម្បីអនុវត្តគោលនយោបាយជាតិឱ្យមានប្រសិទ្ធភាពខ្ពស់ ឆ្ពោះទៅកសាងកម្ពុជាមួយដែលគ្មានការគំរាមកំហែងពីជំងឺអេដស៍។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាស្ថាប័នជំនួយការរបស់រាជរដ្ឋាភិបាលលើការងារដឹកនាំ និងសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ តែងតែបានយកចិត្តទុកដាក់ខ្ពស់លើ **«ភាពជាម្ចាស់»** ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល។ យើងនឹងបន្តធានាឱ្យបាននូវអត្រាគ្របដណ្តប់នៃការផ្តល់សេវា និងការអន្តរាគមន៍នៅទូទាំងប្រទេស ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសហគមន៍។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១. **ការវាយតម្លៃលើការអនុវត្តផែនការឆមាសទី១៖** ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំប្រឹងប្រែងអនុវត្តផែនការសកម្មភាព សម្រាប់រយៈពេល **៦ ខែដើមឆ្នាំ២០២៦** នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ សមិទ្ធផលទាំងនេះ គឺកើតចេញពីការចូលរួមយ៉ាងសកម្ម និងការទទួលខុសត្រូវខ្ពស់ពីសំណាក់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ-អន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២. **ការកោតសរសើរលើការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ៖** ខ្ញុំសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានរួមសហការគ្នាយ៉ាងស្អិតរមួតក្នុងការអនុវត្ត **«គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨»** និង **«ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ លើកទី៦ (២០២៤-២០២៨)»** ឱ្យលេចចេញជាលទ្ធផលជាក់ស្តែង។

៣. **ការវាយតម្លៃខ្ពស់ចំពោះយន្តការហិរញ្ញវត្ថុសាធារណៈ៖** ទន្ទឹមនឹងនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលបានចូលរួមជំរុញឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈការធានាផ្តល់ជម្រុញថវិកា និងការរៀបចំសម្របសម្រួលនីតិវិធីប្រើប្រាស់កញ្ចប់ថវិកាជាតិ ជូនដល់គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ទាំង ២៥។

៤. **ទិសដៅការងារបន្តលើប្រព័ន្ធគាំពារសង្គម៖** ជាទិសដៅទៅមុខ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តសហការយ៉ាងជិតស្និទ្ធជាមួយ**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ** ដើម្បីសិក្សាលើលទ្ធភាពពង្រីកការផ្តល់ និងការប្រើប្រាស់អត្ថប្រយោជន៍គាំពារសង្គម ពិសេស«មូលនិធិសមធម៌សុខាភិបាល» ក្នុងការគាំទ្រដល់ការងារឆ្លើយតបនឹងការរាលដាលមេរោគអេដស៍។ យន្តការនេះ នឹងក្លាយជាឧបករណ៍គន្លឹះក្នុងការលើកទឹកចិត្តឱ្យ «ប្រជាជនគន្លឹះ» ស្ម័គ្រចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍ និងបង្កើនការទទួលបានសេវាថែទាំសុខភាពប្រកបដោយសមធម៌។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១. **ការប្រមូលធាតុចូល និងការរៀបចំផែនការសកម្មភាព៖ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ត្រូវទទួលភារកិច្ចប្រមូលផ្តុំរាល់ធាតុចូល មតិយោបល់ និងអនុសាសន៍ទាំងអស់ដែលត្រូវបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅពិនិត្យ កែសម្រួល និងបញ្ចូលទៅក្នុងគម្រោងផែនការសកម្មភាពនាពេលខាងមុខ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់។

២. **ការលើកកម្ពស់សុខុមាលភាព និងបរិយាកាសអំណោយផល៖** បន្តជំរុញ និងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម ព្រមទាំងបង្កើតបរិយាកាសអំណោយផលប្រកបដោយភាពវិជ្ជមានដើម្បីឱ្យ**ក្រុមប្រជាជនគន្លឹះ** និង**អ្នកផ្ទុកមេរោគអេដស៍** ទទួលបានសេវាបង្ការ-ព្យាបាលមេរោគអេដស៍ សេវាសុខាភិបាល ព្រមទាំងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមផ្សេងៗទៀត ប្រកបដោយសមធម៌ និងប្រសិទ្ធភាព។

៣. **ការពង្រឹងប្រព័ន្ធជាតិ និងចីរភាពកម្មវិធី៖** បន្តជំរុញការពង្រឹងប្រព័ន្ធជាតិ ក្នុងការឆ្លើយតបជា**ពហុវិស័យ** ចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ សំដៅឈានទៅសម្រេចឱ្យបានក្នុងពេលឆាប់ៗនូវ **«ចីរភាពនៃកម្មវិធីអេដស៍នៅកម្ពុជា»**។

៤. **ការបង្កើនប្រសិទ្ធភាពនៃការបង្ការ និងចែកចាយស្រោមអនាម័យ៖** បន្តផ្សព្វផ្សាយ និងអប់រំអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ស្រោមអនាម័យ ១០០% ក្នុងការទប់ស្កាត់ការចម្លងមេរោគអេដស៍ពីដៃគូរួមភេទ ដោយត្រូវធានាឱ្យមានការគ្រប់គ្រង រក្សាទុក និងចែកចាយស្រោមអនាម័យឱ្យបានទូលំទូលាយ នៅតាមទីកន្លែងដែលមានតម្រូវការចាំបាច់នានា ជាពិសេសនៅក្នុងភូមិសាស្ត្រ

ដែលមាន**អាជីវកម្មសេវាកម្សាន្ត** (ដូចជារង្គសាល បៀហ្គាដិន សណ្ឋាគារ ផ្ទះសំណាក់) ឬគ្រប់ទីតាំងដែលមានហានិភ័យខ្ពស់។

៥. **ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការកៀរគរធនធាន៖** បន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធជាពហុវិស័យ ព្រមទាំងជំរុញការផ្លាស់ប្តូរផ្នត់គំនិតក្នុងការអនុវត្តគោលនយោបាយ និងការខិតខំកៀរគរស្វែងរកប្រភពថវិកាឱ្យបានសមស្រប ដើម្បីធានាថាកម្ពុជាយើងនឹងអាចសម្រេចបាននូវ **«គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨»** ទៅតាមកាលកំណត់ដែលបានគ្រោងទុក។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

មុននឹងទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ព្រមទាំងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់** ដែលបានចំណាយពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាថ្ងៃនេះ។ ការចូលរួមយ៉ាងសកម្ម ការផ្តល់នូវមតិយោបល់ល្អៗ ព្រមទាំងការពិភាក្សាដេញដោលប្រកបដោយខ្លឹមសាររបស់យើង ពិតជាបាននាំមកនូវលទ្ធផលល្អប្រសើរ សម្រាប់យកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមមួយកម្រិតទៀត។

ទន្ទឹមនឹងនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ **អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ដែលបានខិតខំប្រឹងប្រែង រៀបចំកិច្ចប្រជុំពេញអង្គនេះឡើង ឱ្យប្រព្រឹត្តទៅបានដោយរលូន តាមការគ្រោងទុក និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គពិធីទាំងមូលជាទីមេត្រី!**

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គលមហាប្រសើរ សេចក្តីសុខ សេចក្តីចម្រើន និងប្រាជ្ញាឈ្លាសវៃ ជូនចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់** ដើម្បីបន្តភារកិច្ចរួមគ្នាជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបានជោគជ័យថ្មីៗបន្ថែមទៀត។

ខ្ញុំសូមប្រកាសបិទ **«កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២៦»** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**